ធ៩-០១០-១៥០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន

# សម្រេច

**ប្រការ ១**.-

ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់ សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរ ឬអេឡិកត្រូនិក ដែលមានទម្រង់ជាការផ្ទេរឥណទាន។

បញ្ជាទូទាត់នេះនឹងត្រូវបានប្រើ ដើម្បីផ្ទេរប្រាក់ពីគណនីរបស់អ្នកសងប្រាក់ទៅគណនីរបស់អ្នកទទួលប្រាក់ដែលគណនីទាំងនេះអាចមាន ឬមិនមាននៅក្នុងធនាគារ ឬសាខាធនាគារជាមួយគ្នា។

**ប្រការ ២**.-

បញ្ជាទូទាត់ត្រូវបានប្រើជាឧបករណ៍ស្របច្បាប់ អនុលោមតាមមាត្រា ១៩៩, ២០០, ២០១ និង ២០២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។ បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានត្រូវបានរៀបចំឱ្យមានលក្ខណៈស្តង់ដារច្បាស់លាស់ និងគ្រប់គ្រាន់ អំពីទម្រង់ ទិន្នន័យ និងព័ត៌មានដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩-០១០-១៥០ ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

## លក្ខណៈស្តង់ដារនៃបញ្ជាទូទាត់

ទម្រង់ ទិន្នន័យ និងព័ត៌មានដែលត្រូវបំពេញនៅក្នុងបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាលាយលក្ខណ៍អក្សរ និងអេឡិកត្រូនិក ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានបី ដូចខាងក្រោម៖

- SWIFT
- សារប័ណ្ណ (Card Message)
- មូលប្បទានប័ត្រស្តង់ដារ ដូចមានចែងនៅក្នុងប្រកាសលេខ ធ៩-០៨-១៨៦ និងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ១- តារាង ទិន្នន័យ និងព័ត៌មាននៃការផ្ទេរឥណទាន

| ឈ្មោះខ្លឹមសារ | ទម្រង់ខ្លឹមសារ | ការពន្យល់ |
|---|---|---|
| លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់ | ៦ ខ្ទង់ | លេខកូដតំណាងឱ្យ " ការផ្ទេរឥណទាន " (ជាកាតព្វកិច្ច) |
| កាលបរិច្ឆេទ | ៨ ខ្ទង់ | ថ្ងៃ-ខែ-ឆ្នាំ (00-00-0000) (ជាកាតព្វកិច្ច) |
| លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីអ្នកសងប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកសងប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្តន័យយោងរបស់អ្នកសងប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |
| ចំនួនប្រាក់ | ១៥ ខ្ទង់ | ១៥ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជា |

| | | |
|---|---|---|
| | | បន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| លេខកូដរូបិយប័ណ្ណ | ៣ ខ្ទង់ | ៣ខ្ទង់តំណាងឱ្យរូបិយប័ណ្ណ ឧទាហរណ៍ KHR ឬ USD (ជាកាតព្វកិច្ច) |
| លេខកូដសុវត្ថិភាព | ១៨ ខ្ទង់ | តំណាងឱ្យលេខកូដសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ (ម៉ាស៊ីនគណនាដោយស្វ័យប្រវត្តិ) |
| លេខសម្គាល់អត្តសញ្ញាណធនាគារទទួលការប្រាក់ | ៦ ខ្ទង់ | ៣ ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីរបស់អ្នកទទួលប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកទទួលប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកទទួលប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |

